ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១០. សរណន

# សារាចរណែនាំ
## ស្តីពី
## ការរៀបចំពិធីបុណ្យកាន់បិណ្ឌ-ភ្ជុំបិណ្ឌ និងកឋិនទាន

* បុណ្យកាន់បិណ្ឌ-ភ្ជុំបិណ្ឌ ជាបុណ្យប្រពៃណីជាតិដ៏សំខាន់របស់ពុទ្ធបរិស័ទខ្មែរគ្រប់រូប ។ ពិធីនេះប្រារព្ធឡើង ដើម្បីឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខ័ន្ធនៃអ្នកមានគុណទាំងឡាយ មានមាតាបិតា ជីដូនជីតា គ្រូឧបជ្ឈាយាចារ្យ បុព្វបុរសជាតិ និងបងប្អូនជនរួមជាតិទាំងឡាយ ដែលបានលាចាកលោកនេះទៅកាន់លោកខាងមុខ ។ ម្យ៉ាងទៀត ពិធីនេះ ក៏ជាឱកាសជួបជុំឪពុក ម្តាយ បងប្អូនញាតិមិត្ត សាច់សាលោហិត ដែលរស់នៅទីផ្សេងៗគ្នា និងអាចស្វែងយល់បានពីសុខទុក្ខ និង ដំណើរប្រព្រឹត្តទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរវាងគ្នានិងគ្នា ទៅវិញទៅមក ព្រមទាំងអាចបង្កើនបាននូវសាមគ្គីភាពដ៏ទូលំទូលាយផង ។

ឆ្នាំនេះ ពិធីបុណ្យកាន់បិណ្ឌ-ភ្ជុំបិណ្ឌ នឹងប្រព្រឹត្តទៅពីថ្ងៃ ១រោច ដល់ថ្ងៃ ១៥រោច ខែ ភទ្របទ ត្រូវនឹង ថ្ងៃទី ២២ ខែ កញ្ញា ដល់ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០២ ។

* បុណ្យកឋិនទាន ជាកាលទានមួយដ៏ថ្លៃថ្លា មានលក្ខណៈពិសេសនៅក្នុងព្រះពុទ្ធសាសនា ដែលក្នុងមួយឆ្នាំមានតែម្តង មានរយៈពេលកំណត់តែ ២៩ ថ្ងៃ វត្តមួយទទួលបានតែអង្គកឋិនមួយ ជាទានមានផលានិសង្សខ្ពស់ ទាំងទាយកទាយិកាអ្នកឱ្យ និងទាំងបដិគ្គាហកៈអ្នកទទួល ជាទីជ្រះថ្លា និងចំណូលចិត្តរបស់ពុទ្ធបរិស័ទខ្មែរ ដែលតែងតែប្រារព្ធធ្វើរៀងរាល់ឆ្នាំ ។ ក្រៅពីនេះ តាមរយៈកឋិនទាន វត្តនិមួយៗក៏មានលទ្ធភាពអាចនឹងទទួលបាននូវសម្ភារៈ ថវិកាយ៉ាងច្រើន បំរើការកសាងទីសេនាសនៈនៅក្នុងវត្ត មានព្រះវិហារ កុដិ សាលា និងជួយឧបត្ថម្ភដល់ការកសាងសមិទ្ធផលសង្គម និងវិស័យសង្គមកិច្ច ផងថែមទៀត ។

ឆ្នាំនេះ កឋិនទាន នឹងត្រូវប្រព្រឹត្តទៅពីថ្ងៃ ១រោច ខែ អស្សុជ ដល់ថ្ងៃ ១៥ កើត ខែ កត្តិក ត្រូវនឹងថ្ងៃទី ២២ ខែ តុលា ដល់ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ ។

ដើម្បីបើកឱកាសប្រគេនព្រះសង្ឃ ជូនពុទ្ធបរិស័ទបំពេញកុសលតាមសទ្ធាជ្រះថ្លា ជូនបុត្តធីតា បងប្អូន សិស្សានុសិស្ស មានលទ្ធភាពធ្វើបដិការៈគោរពតបស្នងសងគុណ មាតាបិតា ជីដូនជីតា អាណាព្យាបាល គ្រូឧបជ្ឈាយាចារ្យ តាមជំនឿនិងបានរួមចំណែកថែរក្សានូវប្រពៃណីទំនៀមទម្លាប់និងអត្តសញ្ញាណជាតិ ឱ្យបានគង់វង្ស រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការណែនាំដូចតទៅនេះ :

១- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង ត្រូវផ្សព្វផ្សាយអំពីខ្លឹមសារពិធីបុណ្យទាំងពីរខាងលើ ឱ្យបានជ្រួតជ្រាបទូលំទូលាយ និងបំផុសលើកទឹកចិត្ត បង្កលក្ខណៈងាយស្រួល ឱ្យមន្ត្រីរាជការ

ក្នុងឱកាសជាពុទ្ធសាសនិក បានចូលរួមបំពេញបុណ្យកុសល ជាប្រពៃណី នៅតាមវត្តអារាម ឬនៅក្នុងអង្គភាពរបស់ខ្លួន ព្រមទាំងបានជួបជុំឪពុក ម្តាយ បងប្អូន ជីដូន ជីតា តាមបំណងប្រាថ្នា ។

២- ក្រសួងធម្មការនិងសាសនា ត្រូវធ្វើការណែនាំលំអិតដល់មន្ទីរធម្មការ និងសាសនាខេត្ត-ក្រុង យកចិត្តទុកដាក់បង្កលក្ខណៈឱ្យបានល្អប្រសើរ ប្រគេនព្រះសង្ឃ ជូនពុទ្ធបរិស័ទ ប្រារព្ធពិធីកាន់បិណ្ឌ-ភ្ជុំបិណ្ឌ និងបុណ្យកឋិនទាន តាមប្រពៃណីព្រះពុទ្ធសាសនា និងទំនៀមទម្លាប់ជាតិ ដោយសទ្ធាជ្រះថ្លា តាមពេលវេលាកំណត់ ។

គ្រប់វត្តអារាម ត្រូវរៀបចំបោសសំអាតបូជនីយដ្ឋាន ស្តូប កន្លែងតម្កល់អដ្ឋិធាតុ បងប្អូនជនរួមជាតិ ដែលបានបាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍ និងរៀបចំបង្សុកូល ឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធ បុព្វបុរស ដែលបានពលីក្នុងបុព្វហេតុជាតិមាតុភូមិ និងជនរួមជាតិយើងទាំងនោះ តាមប្រពៃណីព្រះពុទ្ធសាសនា ។

រាល់ផលទាន ដែលកើតឡើងដោយពិធីបុណ្យទាំងពីរខាងលើ មានម្ហូបអាហារ និងចំណីជាដើម គប្បីវិភាគចែកជូនដល់បងប្អូនក្រីក្រ បងប្អូនពិការ កុមារកំព្រា តាមលទ្ធភាពរបស់វត្តនិមួយៗ ជាពិសេស សម្ភារៈ ថវិកា ត្រូវណែនាំឱ្យមានការគ្រប់គ្រង និងប្រើប្រាស់ឱ្យបានត្រឹមត្រូវ សមហេតុផល ជៀសវាងការបាត់បង់ដោយប្រការផ្សេងៗ និងបង្កឱ្យមានទៅជាទំនាស់បែកបាក់សាមគ្គី ដែលនឹងអាចកើតមានដោយថាហេតុ ។

គ្រប់អ្នកផ្តួចផ្តើមដង្ហែអង្គកឋិន ត្រូវត្រួតពិនិត្យមើលឱ្យបានគ្រប់ជ្រុងជ្រោយ នូវប្រភេទក្មេងស្ទាវ ដែលចូលរួមដង្ហែអង្គកឋិន ព្រោះអាចមានមនុស្សមិនសុចរិត បង្កសកម្មភាព អាចនាំឱ្យមានទំនាស់រវាងក្រុមមួយទៅក្រុមមួយ ធ្វើឱ្យខូចតម្លៃនៃបុណ្យកឋិនទាន ។

៣- អាជ្ញាធរគ្រប់ថ្នាក់ ត្រូវធ្វើការណែនាំ និងអប់រំយុវជន យុវនារី កុមារា កុមារី ដែលចូលរួមដង្ហែអង្គកឋិន ឱ្យយល់ពីតម្លៃនៃពិធីបុណ្យដ៏ឧត្តុង្គឧត្តមនេះ ហើយចេះធ្វើខ្លួនឱ្យស័ក្តិសមជាកូនចៅរបស់ពុទ្ធសាសនិកពិតប្រាកដ ដោយមិនបង្កសកម្មភាពនាំឱ្យប៉ះពាល់ដល់កិត្តិយសព្រះពុទ្ធសាសនា ដូចជាការគប់ស្បោងទឹក ជះទឹក គប់អំពៅ គប់ផ្លែឈើ និងគប់ដោយវត្ថុរឹងផ្សេងៗ ធ្វើឱ្យខូចរបៀបរៀបរយ សណ្តាប់ធ្នាប់សង្គម និងអាចឈានទៅរកគ្រោះថ្នាក់ដោយអំពើលេងសើចគ្មានរបៀបនេះ ។

៤- ក្រសួងព័ត៌មាន ត្រូវណែនាំឱ្យបណ្តាញឃោសនា វិទ្យុ ទូរទស្សន៍ជាតិ ឯកជន អ្នកយកព័ត៌មាន តាមដានស្វែងយល់ ស្រាវជ្រាវប្រវត្តិខ្លឹមសារ និងសកម្មភាពនៃពិធីបុណ្យប្រពៃណី និងអំពីរបៀបរបបស្លៀកពាក់ ក៏ដូចជាអាកប្បកិរិយា ឫកពា សុភាពរាបសារ ដែលត្រូវប្រកាន់យកក្នុងពេលចូលរួមពិធីបុណ្យប្រពៃណីនេះ នៅក្នុងវត្តអារាម ផ្សព្វផ្សាយឱ្យបានទូលំទូលាយ ។

៥- ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវណែនាំដល់អង្គភាពក្រោមឱវាទ ឱ្យសហការការពារសន្តិសុខ របៀបរៀបរយសណ្តាប់ធ្នាប់សង្គម បង្កលក្ខណៈ ប្រគេនព្រះសង្ឃ ជូនពុទ្ធបរិស័ទ បំពេញបុណ្យកុសលតាមជំនឿ និងធានាសុវត្ថិភាព សប្បាយរីករាយ ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សង្ឃឹមថា ថ្នាក់ដឹកនាំគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងគ្រប់ខេត្ត-ក្រុង និងចាត់តាំងអនុវត្តស្មារតីសារាចរណែនាំនេះ ឱ្យបានសម្រេច លទ្ធផលល្អប្រសើរ ស្របតាមប្រពៃណីជាតិដ៏រុងរឿងរបស់យើង ។/.

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០០២

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ